**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករទូរគមនាគមន៍កម្ពុជា**

លេខ : ៧៧៩២ .ន.ទ.ក.

**សូមជម្រាបជូន**

**លោកជំទាវ ឧត្តមសេនីយ៍ឯកវេជ្ជបណ្ឌិត អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**

**នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**កម្មវត្ថុ** : ករណីនៃសំណើសុំជួយជំរុញឱ្យមានសកម្មភាពផ្សព្វផ្សាយខ្លឹមសារអប់រំ តាមរយៈសារសំឡេងក្នុងទម្រង់ Call Ring Back Tone (CRBT) និងសារ (SMS) នៅគ្រប់បណ្តាក្រុមហ៊ុនផ្តល់សេវាកម្មទូរស័ព្ទចល័ត ដើម្បីអបអរសាទរទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស លើកទី៧ ឆ្នាំ២០២៣។

**យោង** : លិខិតលេខ ១២៣/២៣ សណ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបលោក**ជំទាវ ឧត្តមសេនីយ៍ឯកវេជ្ជបណ្ឌិត** ជ្រាបថា ដើម្បីចូលរួមអបអរសាទរទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្សលើកទី៧ ឆ្នាំ២០២៣ និងស្របតាមការអនុវត្តកន្លងមក ទាក់ទងនឹងសារខ្លី (SMS) អប់រំដូចជា បញ្ហាគ្រឿងញៀន បញ្ហាសុវត្ថិភាពចរាចរណ៍ផ្លូវគោក ការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍និងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ និយ័តករទូរគមនាគមន៍កម្ពុជាបានណែនាំឱ្យប្រតិបត្តិករទូរស័ព្ទចល័តទាំងអស់ ត្រូវផ្សព្វផ្សាយសារខ្លី (SMS) អប់រំ ទៅកាន់អ្នកប្រើប្រាស់សេវាទូរស័ព្ទចល័តគ្រប់រូបនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៣ ទៅតាមខ្លឹមសារដែលគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានកំណត់ដូចខាងក្រោម÷

" ទោះបីជាសាសនិកសាសនាណាក៏អាចក្លាយជាជនរងគ្រោះដោយអំពើជួញដូរមនុស្សបាន សូមកុំធ្វេសប្រហែស!"

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោក**ជំទាវ ឧត្តមសេនីយ៍ឯកវេជ្ជបណ្ឌិត** ជ្រាបដោយសេចក្តីអនុគ្រោះ។

សូមលោក**ជំទាវ ឧត្តមសេនីយ៍ឯកវេជ្ជបណ្ឌិត** ទទួលនូវការគោរពរាប់អានពីខ្ញុំ។

ថ្ងៃ អង្គារ ១៥កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ០៨ ឆ្នាំ២០២៣

**ប្រធានស្តីទី**

**ស្រ៊ុន គីមសាន**

**ចម្លងជូន :**

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- ឯកសារ-កាលប្បវត្តិ